ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៤៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ១.១៦៥,៥ ហិកតា នៅឃុំអំពិលប្រាំដើម ស្រុកបវេល ខេត្តបាត់ដំបង ក្នុងនោះ កាត់ចេញពីដីដែនជម្រកសត្វព្រៃរនាមដូនសំ និងកាត់ចេញ ពីដីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣០៤ គ្រួសារ និងការផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង

របស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១១៣/១២៥៣ ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១០១៣ ឧបប ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- លិខិតលេខ ១១៧០ ឧបប ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ១.១៦៥,៥ ហិកតា ក្នុងនោះ (១) ទំហំ ៦០ ហិកតា កាត់ចេញពីដីដែនជម្រកសត្វព្រៃរនាមដូនសំ ដោយព្រះរាជក្រឹត្យលេខ នស/រកត/១១១៣/១២៥៣ ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ និង (២) ទំហំ ១.១០៥,៥ ហិកតា កាត់ចេញពីដីតម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិបឹង អារ៉ែក្ស ឃុំអំពិលប្រាំដើម ស្រុកបវេល ខេត្តបាត់ដំបង តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូន គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង ចំនួន ៣០៩ គ្រួសារ នៅភូមិបឹងអារ៉ែក្ស ឃុំអំពិលប្រាំដើម ស្រុកបវេល ខេត្តបាត់ដំបង ។

**មាត្រា ៣:** ផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុប ៩៧៩ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ៩៧១ ក្បាលដី ជូនប្រជាពលរដ្ឋ ៣០៩ គ្រួសារ អចលនវត្ថុរបស់វត្ត ០១ ក្បាលដី និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០៣ ក្បាលដី (ដីស្រះទឹក ០២ ក្បាលដី និងដីសាលារៀន ០១ ក្បាលដី) នៅភូមិបឹងអារ៉ែក្ស ឃុំអំពិលប្រាំដើម ស្រុកបវេល ខេត្តបាត់ដំបង ។

**មាត្រា ៤:** ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥:** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*



www.pheakdeylaw.com

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៥៤៩ អនក្រ.បក ចុះថ្ងៃទី ០២ ខែ ធ ឆ្នាំ២០១៣ ស្តីពីការកាត់ដីទំហំ ១១៦៥,៥ ហិកតា នៅឃុំអំពិលប្រាំដើម ស្រុកបវេល ខេត្តបាត់ដំបង ចេញពីដែនជម្រកសត្វព្រៃនាមជុនសី និងកាត់ចេញពីដីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣០៤ គ្រួសារ និងការផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី**




| ចំនុចនិយាមការ | | |
|---|---|---|
| ល.រ | X | Y |
| 1 | 256048 | 1464306 |
| 2 | 256092 | 1463621 |
| 3 | 257087 | 1463739 |
| 4 | 257110 | 1463197 |
| 5 | 256065 | 1463059 |
| 6 | 256038 | 1462221 |
| 7 | 256137 | 1461349 |
| 8 | 255868 | 1461373 |
| 9 | 255639 | 1461080 |
| 10 | 255114 | 1461122 |
| 11 | 254929 | 1461277 |
| 12 | 254190 | 1461432 |
| 13 | 253936 | 1461427 |
| 14 | 253904 | 1460986 |
| 15 | 252600 | 1461309 |
| 16 | 252607 | 1462132 |
| 17 | 252561 | 1462168 |
| 18 | 252578 | 1462757 |
| 19 | 252434 | 1462787 |
| 20 | 252316 | 1463019 |
| 21 | 252350 | 1463410 |
| 22 | 251785 | 1463525 |
| 23 | 251723 | 1464730 |
| 24 | 252686 | 1464569 |
| 25 | 254566 | 1463593 |
| 26 | 254569 | 1463807 |
| 27 | 255405 | 1463874 |
| 28 | 255384 | 1464293 |



<u>ប្រព័ន្ធកូអរដោនេ :</u>

*តំបន់ទី : 48N*

*ចំណោលផែនទី : UTM*

*ទិន្នន័យយោង : WGS 1984*

<u>ប្រភពទិន្នន័យ:</u>

*ព្រំប្រទល់: នាយកដ្ឋានភូមិសាស្ត្រ*

*គំរបព្រៃ: រដ្ឋបាលព្រៃឈើ ឆ្នាំ ២០០២*

<u>គម្របព្រៃឈើ</u>

- ព្រៃរបោះ
- ព្រៃស្រោង
- ព្រៃផ្សេងៗ
- ព្រៃពាក់កណ្តាលស្រោង
- ដីមិនមែនព្រៃ
- ព្រំប្រទល់ដីស្នើសុំ